**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធនធានទឹក និងឧតុនិយម**

លេខ ០៥៣ សជណ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពសីតុណ្ហភាពមធ្យមអតិបរមា នៅព្រះរាជាណាចក្រកម្ពុជា
## ( ចាប់ពីថ្ងៃទី 20 ខែកុម្ភៈ ដល់ដើមខែឧសភា ឆ្នាំ 2014 )

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាប អំពីស្ថានភាពសីតុណ្ហភាពមធ្យមអតិបរមា នៅព្រះរាជាណាចក្រកម្ពុជា ( ចាប់ពីថ្ងៃទី 20 ខែកុម្ភៈ ដល់ដើមខែឧសភា ឆ្នាំ 2014 ) ដូចខាងក្រោម :

1- **តំបន់ខ្ពង់រាបភាគឦសាន និងខ្ពង់រាបភាគខាងជើង** : រួមមានខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រះវិហារ និងខេត្តឧត្តរមានជ័យ :

- ចាប់ពីថ្ងៃទី 20 ខែកុម្ភៈ ដល់ដើមសប្តាហ៍ទី 1 ខែមេសា សីតុណ្ហភាពអតិបរមាមានពី 33-35 °C
- ចាប់ពីដើមខែមេសា ដល់ដើមខែឧសភា សីតុណ្ហភាពអតិបរមាមានពី 35-37 °C
- ស្ថានភាពភ្លៀងកក់ខែ : នឹងមានកម្រិតតិចជាងឆ្នាំ 2013 ។

2- **តំបន់ទំនាបកណ្តាល** : រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប កំពង់ធំ ព្រៃវែង ស្វាយរៀង តាកែវ និងខេត្តកំពង់ស្ពឺ :

- ចាប់ពីថ្ងៃទី 20 ខែកុម្ភៈ ដល់ដើមសប្តាហ៍ទី 1 ខែមេសា សីតុណ្ហភាពអតិបរមាមានពី 33-36 °C
- ចាប់ពីដើមខែមេសា ដល់ដើមខែឧសភា សីតុណ្ហភាពអតិបរមាមានពី 36-38 °C
- ស្ថានភាពភ្លៀងកក់ខែ : នឹងមានកម្រិតតិចជាងឆ្នាំ 2013 ។

3- **តំបន់មាត់សមុទ្រ** : រួមមានខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប :

- ចាប់ពីថ្ងៃទី 20 ខែកុម្ភៈ ដល់ដើមសប្តាហ៍ទី 1 ខែមេសា សីតុណ្ហភាពអតិបរមាមានពី 29-31 °C
- ចាប់ពីដើមខែមេសា ដល់ដើមខែឧសភា សីតុណ្ហភាពអតិបរមាមានពី 31-34 °C
- ស្ថានភាពភ្លៀងកក់ខែ : នឹងមានកម្រិតប្រហាក់ប្រហែលទៅនឹងឆ្នាំ 2013 ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**លឹម គានហោ**